# អធិដ្ឋានពិសេសរបស់លោកអភិបាល អូលីវីយេ
# សម្រាប់ទិវានៃការត្រាស់ហៅនៅភ្នំពេញ
# កំពត ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០

ឱព្រះយេស៊ូជាអម្ចាស់ នៅពេលនេះយើងជាយុវជនយុវនារីយើងកំពុងសម្លឹងមើលព្រះអង្គដែលនៅខាងមុខ ព្រះអង្គដែលជាព្រះកាយព្រះគ្រីស្តដោយបានបូជាជីវិតសម្រាប់យើង។ នៅពេលនេះ យើងបានស្តាប់ព្រះអង្គដែលមានព្រះបន្ទូលដល់យើង "**ខ្ញុំជាអាហារដែលផ្តល់ជីវិតអស់កល្បជានិច្ច គឺព្រះបិតារបស់ខ្ញុំដែលទាក់ទាញឲ្យមនុស្សមករកខ្ញុំ**"។

ឱព្រះយេស៊ូអើយ នៅពេលនេះព្រះអង្គកំពុងទាក់ទាញយុវជនយុវនារីនៅក្នុងប្រទេសកម្ពុជាដើម្បីរកព្រះអង្គ ដើម្បីដើរតាមព្រះអង្គ ដើម្បីទទួលអាហារដែលផ្តល់ជីវិតអស់កល្បជានិច្ច។ ចំការរបស់យើងធំណាស់ ប៉ុន្តែមានកសិករតិចណាស់។

ឱព្រះយេស៊ូគ្រីស្តអើយ សូមបំភ្លឺយុវជនយុវនារីរបស់យើង ឲ្យគេស្តាប់ព្រះបន្ទូលរបស់ព្រះអង្គដែលបានប្រាប់គេថា "**ដល់ពេលវេលាដើម្បីឆ្លើយតប ដល់ពេលវេលាដើម្បីក្រោកឈរឡើង ដល់ពេលវេលាដើម្បីដើរតាមព្រះអង្គនិងប្រកាសដំណឹងល្អ ដល់ពេលវេលាលះបង់ចោលជីវិតដើម្បីទទួលជីវិតអស់កល្បជានិច្ច**"។

ព្រះយេស៊ូកំពុងគង់នៅជាមួយយើង កំពុងយាងចូលនៅក្នុងដួងចិត្តរបស់យុវជនយុវនារីដើម្បីឲ្យយុវជនយុវនារីយ៉ាងច្រើនចូលនៅក្នុងក្រុមគ្រីស្តទូត ដើម្បីប្រកាសដំណឹងល្អ ដើម្បីបម្រើអ្នកក្រីក្រអ្នកតូចតាចនិងមនុស្សទាំងអស់ និងដើម្បីអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ជានិច្ច។

ព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជា ទន្ទឹងរង់ចាំយុវជនយុវនារីដើម្បីធ្វើជាអ្នកបម្រើ អ្នកស្រឡាញ់ អ្នកអធិដ្ឋានឲ្យព្រះសហគមន៍របស់យើង ឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់លើទឹកដីយើង អាចទទួលជីវិតដែលចុះពីស្ថានបរមសុខ ជីវិតដែលមកពីព្រះអង្គផ្ទាល់។

ប្អូនៗដែលជាយុវជនយុវនារី សូមសម្លឹងមើលព្រះកាយព្រះគ្រីស្តដែលនៅខាងមុខ សូមបើកត្រចៀក សូមបើកដួងចិត្ត គឺព្រះយេស៊ូផ្ទាល់ដែលកំពុងយាងចូលនៅក្នុងជីវិតរបស់យើង គឺព្រះយេស៊ូផ្ទាល់ដែលកំពុងយាងចូលនៅក្នុងបេះដូងរបស់ប្អូនៗ។

ព្រះយេស៊ូមានព្រះបន្ទូលដល់ប្អូនៗថា "**ខ្ញុំត្រូវការប្អូន ខ្ញុំចាត់ឲ្យទៅដើម្បីប្រកាសដំណឹងល្អ ដើម្បីបម្រើ ដើម្បីស្រឡាញ់ និងដើម្បីអធិដ្ឋាន**"។

បពិត្រព្រះយេស៊ូគ្រីស្តជាអម្ចាស់ ព្រះអង្គបានប្រទានអគ្គសញ្ញានៃព្រះកាយព្រះអង្គ ទុកជាការនឹករលឹកពីទុក្ខលំបាករបស់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោសយើងខ្ញុំឲ្យយកចិត្តទុកដាក់គោរពអគ្គសញ្ញាដ៏ប្រសើរឧត្តមនេះ និងទទួលស្គាល់សេចក្តីស្រឡាញ់ដ៏លើសលប់របស់ព្រះអង្គផង។

ព្រះអង្គមានព្រះជន្មគង់នៅ និងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន។

*សូមលើកតម្កើងព្រះជាម្ចាស់ សូមលើកតម្កើងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ សូមលើកតម្កើងព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ដ៏ពិតប្រាកដនិងជាមនុស្សដ៏ពិតប្រាកដ។*
*សូមលើកតម្កើងព្រះនាងព្រះយេស៊ូ សូមលើកតម្កើងព្រះបេះដូងដ៏សក្ការរបស់ព្រះអង្គ សូមលើកតម្កើងព្រះលោហិតដ៏ពិសិដ្ឋរបស់ព្រះអង្គ សូមលើកតម្កើងព្រះកាយព្រះយេស៊ូដែលគង់នៅលើអាសនៈ។*
*សូមលើកតម្កើងព្រះវិញ្ញាណដ៏វិសុទ្ធដែលជួយសម្រាលទុក្ខ សូមលើកតម្កើងព្រះនាងព្រហ្មចារិនីដ៏វិសុទ្ធជាព្រះមាតានៃព្រះជាម្ចាស់ ដែលគ្មានអ្វីប្រៀបផ្ទឹមបាន។*
*សូមលើកតម្កើងភាពដ៏វិសុទ្ធ និងភាពគ្មានជំពាក់បាបរបស់ព្រះនាង សូមលើកតម្កើងការឡើងស្ថានបរមសុខដ៏រុងរឿងរបស់ព្រះនាង សូមលើកតម្កើងព្រះនាមនៃព្រះនាងម៉ារីជាព្រះមាតានិងជាព្រហ្មចារិនី។*
*សូមលើកតម្កើងសន្តយ៉ូសែបជាស្វាមីដ៏ស្មោះត្រង់របស់ព្រះនាង សូមលើកតម្កើងព្រះជាម្ចាស់ក្នុងចំណោមពួកទេវទូតនិងសន្តបុគ្គលរបស់ព្រះអង្គ។*
*ឱព្រះជាម្ចាស់អើយ សូមប្រទានបូជាចារ្យនិងបងស្រីមកយើងខ្ញុំ*
*ឱព្រះជាម្ចាស់អើយ សូមប្រទានបូជាចារ្យនិងបងស្រីជាច្រើនមកយើងខ្ញុំ*
*ឱព្រះជាម្ចាស់អើយ សូមប្រទានបូជាចារ្យនិងបងស្រីដ៏វិសុទ្ធជាច្រើនមកយើងខ្ញុំ។*

**សូមបងប្អូនតាំងចិត្តអធិដ្ឋាន**

បពិត្រព្រះបិតាជាអម្ចាស់ នៅពេលនេះព្រះយេស៊ូព្រះគ្រីស្តគង់នៅជាមួយយើង ដើម្បីទាក់ទាញឲ្យយុវជនយុវនារីទៅរកព្រះអង្គផ្ទាល់នៅក្នុងជីវិតគេ។ នៅពេលនេះដែរ យើងជាប្រជារាស្ត្រទូទាំងប្រទេសកម្ពុជាទូលអង្វរព្រះអង្គ សូមព្រះអង្គការពារថែរក្សាប្រទេសយើង ការពារថែរក្សាប្រជាជនយើង ការពារថែរក្សាសុខភាពយើង ការពារថែរក្សាសុខដមរមនានិងសេចក្តីសង្ឃឹមសេចក្តីសុខសាន្តនៅក្នុងសង្គមបច្ចុប្បន្ននេះ។

បពិត្រព្រះអម្ចាស់ នៅពេលនេះយើងអធិដ្ឋានសម្រាប់ពិភពលោកទាំងមូល ដែលកំពុងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ វាបានណែនាំឲ្យមនុស្សជាច្រើនទទួលមរណភាព និងកំពុងបន្តទទួលមរណភាពទៀត។

បពិត្រព្រះអម្ចាស់ នៅពេលនេះយើងផ្ញើគ្រួសារបងប្អូនទាំងអស់ដែលកំពុងភ្ជាប់នឹងជំងឺកូវីដ១៩ យើងផ្ញើសង្គមនីមួយៗជាពិសេសសង្គមនៅប្រទេសកម្ពុជា ដែលពីមួយថ្ងៃទៅមួយថ្ងៃកំពុងទទួលឥទ្ធិពលយ៉ាងអាក្រក់បំផុតនៅក្នុងជីវិតប្រចាំថ្ងៃ ដើម្បីសម្រុះសម្រួលទាំងម្ហូបអាហារ ទាំងជីវិតប្រចាំថ្ងៃ ទាំងការសិក្សា។

បពិត្រព្រះអម្ចាស់ជាព្រះបិតា សូមគង់នៅជាមួយយើងដើម្បីការពារថែរក្សាជំនឿរបស់យើង សេចក្តីសង្ឃឹមរបស់យើង និងសេចក្តីស្រឡាញ់របស់យើងជានិច្ច ដើម្បីឲ្យយើងដែលជាព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជារួមគ្នា យើងអាចទៅជាសាក្សីនៃជីវិតដែលព្រះអង្គប្រទានឲ្យយើង ជាជីវិតមកពីស្ថានបរមសុខគឺជីវិតអស់កល្បជានិច្ច។

យើងរួមគ្នាផ្ញើទុក្ខលំបាករបស់យើង ការឈឺចាប់របស់យើង ទៅលើព្រះជាម្ចាស់តាមរយៈព្រះកាយព្រះគ្រីស្ត។ ជាពិសេស នៅពេលនេះសូមព្រះអង្គប្រទានពរសម្រាប់ពិភពលោក ប្រទានពរសម្រាប់ព្រះសហគមន៍និងប្រទេសកម្ពុជា ប្រទានពរដល់ព្រះសហគមន៍យើងនៅក្នុងភូមិភាគភ្នំពេញ រួមជាមួយយុវជនយុវនារី រួមជាមួយអ្នកដែលកំពុងទទួលស្វែងយល់ព្រះបន្ទូល ជំហានទីពីរ គ្រីស្តបរិស័ទ បូជាចារ្យ បងប្រុសបងស្រី យើងជាប្រជារាស្ត្រព្រះជាម្ចាស់ដែលជាសាក្សីនៃជីវិតដែលយើងមាននៅមុខយើងនៅពេលនេះ។ យើងទូលអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូដែលជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។ អាម៉ែន៕